**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## ទិវាសេរីភាពសារព័ត៌មានពិភពលោក ៣ ឧសភា ២០១៦

ទីក្រុងហ្សឺណែវ (៣ ឧសភា ២០១៦) - អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសេរីភាពសម្តែងមតិ លោក ដាវីដ កៃយេ (David Kaye) នៅថ្ងៃនេះ បានព្រមានថា កិច្ចខិតខំប្រឹងប្រែងដើម្បីប្រឆាំងនឹង "អំពើជ្រុលនិយមហិង្សា" អាចជា "លេសឥតខ្ចោះមួយ" សម្រាប់រដ្ឋាភិបាលប្រជាធិបតេយ្យ និងរដ្ឋាភិបាលផ្តាច់ការ នៅជុំវិញពិភពលោក ដើម្បីរឹតត្បិតការសម្តែងមតិដោយសេរី និងស្វែងរកការត្រួតពិនិត្យលើសិទ្ធិទទួលព័ត៌មាន។

ទន្ទឹមនឹងទទួលស្គាល់ថា វាជាការចាំបាច់សម្រាប់រដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋទាំងឡាយ ក្នុងការប្រឆាំងនឹងអំពើហិង្សា និងការញុះញង់ឲ្យមានអំពើហិង្សានោះ លោក កៃយេ និងសមភាគីរបស់លោកមកពីគណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន គណៈកម្មការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការទទួលបន្ទុកសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) លើកឡើងអំពីកង្វល់នៅក្នុងសេចក្តីប្រកាសរួមប្រចាំឆ្នាំរបស់ខ្លួន* ថា កម្មវិធីប្រឆាំងនឹង ហានិភ័យ "អំពើជ្រុលនិយមហិង្សា" ឬហៅកាត់ថា (កម្មវិធីប្រឆាំងនឹងអំពើជ្រុលនិយមហិង្សា (CVE) ឬកម្មវិធីបង្ការអំពើជ្រុលនិយមហឹង្សា (PVE)) ដែលធ្វើឲ្យថមថយនូវសេរីភាពសម្តែងមតិ។

"ដោយ 'ធ្វើឲ្យមានសតុល្យ' នូវសេរីភាពសម្តែងមតិ និងការបង្ការអំពើហិង្សា កម្មវិធី និងគំនិតផ្តួចផ្តើមទាំងនេះសំដៅប្រឆាំង 'អំពើហឹង្សាជ្រុលហិង្សា' ជារឿយៗដោយចេតនា ជួនកាលដោយអចេតនា - បាននាំឲ្យមាន ហានិភ័យ ឬកាត់បន្ថយឯករាជភាពនៃប្រព័ន្ធផ្សព្វផ្សាយ" អ្នកជំនាញ អ.ស.ប បានមានប្រសាសន៍នៅក្នុងឱកាសទិវាសេរីភាពសារព័ត៌មានពិភពលោក។

"អ្វីដែលគេហៅថា កម្មវិធី CVE ឬ PVE ត្រូវតែបានផ្អែកលើក្របខ័ណ្ឌច្បាប់មួយ និងផ្អែកលើភស្តុតាងនៃប្រសិទ្ធិភាព និងចាំបាច់របស់កម្មវិធីនេះទាំងនេះ និងសមាមាត្រភាពដើម្បីសម្រេចគោលដៅស្របច្បាប់" នេះបើតាមការគូសបញ្ជាក់របស់លោក **កៃយេ**។

អ្នកជំនាញការសិទ្ធិមនុស្សបានកត់សម្គាល់ថា កម្មវិធី CVE ភាគច្រើន មិនបានផ្តល់និយមន័យនៃពាក្យគន្លឹះមួយចំនួន ដូចជា 'ជ្រុលនិយម' ឬ 'មូលវិវិឌ្ឍកម្ម' ឡើយ។ លោកបានមានប្រសាសន៍ថា៖ "ដោយមិនមាននិយមន័យច្បាស់លាស់ ពាក្យទាំងនេះអាចត្រូវបានគេប្រើ ដើម្បីរិតត្បិតការសម្តែងមតិស្របច្បាប់ជាច្រើន"។

លោក កៃយេ គ្រើនរំលឹកថា៖ "រដ្ឋាភិបាលមួយចំនួនកំណត់គោលដៅលើអ្នកសារព័ត៌មាន អ្នកសរសេរប្លុក អ្នករិះគន់ផ្នែកនយោបាយ សកម្មជន និងអ្នកការពារសិទ្ធិមនុស្ស ថាជា "អ្នកជ្រុលនិយម" ឬ "ភេរវករ" ដោយដាក់ជាបទល្មើស និងឃាត់ខ្លួនពួកគេ ដោយប្រើប្រព័ន្ធច្បាប់ដើម្បីប្រឆាំងនឹងបទល្មើសទូលំទូលាយ និងមិនច្បាស់លាស់"។ "អារម្មណ៍ថាមានគ្រោះថ្នាក់គឺកើតមានចំពោះមិនត្រឹមតែអ្នកសារព័ត៌មានប៉ុណ្ណោះទេ គឺកើតមានចំពោះអ្នកអាន/អ្នកមើលរបស់អ្នកសារព័ត៌មាន សារធារណជន ផងដែរ ថាសមនឹងទទួលបានសិទ្ធិក្នុងការដឹងនិងទទួលបានព័ត៌មានអំពីផលប្រយោជន៍សាធារណៈ"។

អ្នករាយការណ៍ពិសេសក៏គ្រើនរំលឹកផងដែរថាកិច្ចខិតខំប្រឹងប្រែងបំផុសឲ្យមានការប្រឆាំងនឹងជ្រុលនិយមហិង្សា (CVE) រាប់ទាំង ការដកយកចេញនូវមាតិកា ការឈ្លបយកការណ៍ ការស្តីបន្ទោសអំពីឧបករណ៍សុវត្ថិភាព ដូចជា ការអ៊ិនគ្រីប, ហានិភ័យដែលធ្វើឲ្យថមថយដល់សក្តានុពលនៃបច្ចេកវិទ្យាឌីជីថលក្នុងការលើកស្ទួយសេរីភាពសម្តែងមតិ និងសិទ្ធិទទួលបានពត័មាន និងការផ្តល់នូវមធ្យោបាយដើម្បីប្រឆាំងការបញ្ចេញមតិ។

លោក កៃយេ បានមានប្រសាសន៍ថា "សេរីភាពសម្តែងមតិដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកស្ទួយសមភាពនិងប្រយុទ្ធប្រឆាំងនឹងការមិនអត់ឱន និងតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ អ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថលផ្សេងទៀត ក្នុងការបន្តជូនដំណឹងដល់សង្គមគឺមានសារៈសំខាន់ណាស់"។

សម្រាប់អ្នករាយការណ៍ពិសេស "ការដាក់កំហិតលើលំហសេរីភាពសម្តែងមតិ និងការរិតត្បិតលើលំហាពលរដ្ឋជម្រុញឲ្យសម្រេចបានគោលដៅរបស់អ្នកដែលកំពុងបង្កឲ្យមាន, គំរាមកំហែង និងប្រើប្រាស់អំពើភេរវកម្ម និងអំពើហិង្សា"។

(*) **សូមមើលសេចក្តីថ្លែងការណ៍រួម**ស្តីពីសេរីភាពសម្តែងមតិ និងប្រឆាំងអំពើរជ្រុលនិយមហិង្សា ដោយអ្នករាយការពិសេសរបស់អ.ស.បស្តីពីសេរីភាពនៃគំនិត និងការសម្តែងមតិ លោក ដេវីត កៃយេ (David Kaye), តំណាងទទួលបន្ទុកសេរីភាពប្រព័ន្ធផ្សព្វផ្សាយរបស់អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការអ៊ឺរ៉ុប (OSCE) លោកស្រី ឌុនចា មីចាតូវិច (Dunja Mijatovic), អ្នករាយការពិសេសស្តីពីសេរីភាពសម្តែងមតិរបស់គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស លោក អេឌីស៊ុន លែនហ្សា (Edison Lanza), អ្នករាយការពិសេសស្តីពីសេរីភាពសម្តែងមតិ និងសិទ្ធិទទួលបានព័ត៌មានរបស់គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ACHPR) លោកស្រី ប៉ាន់ស៊ី ថ្លាកូឡា (Pansy Tlakula) អាចរកបាននៅ៖http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=19915&LangID=E

ចប់

*លោក* ***ដាវីដ កៃយេ*** *(អាមេរិក) ត្រូវបានតែងតាំងជា អ្នកករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពនៃគំនិត និងការសម្តែងមតិ នៅខែសីហា ឆ្នាំ២០១៤ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ដែលជាស្ថាប័នធំបំផុតមួយរបស់អ្នកជំនាញការឯករាជ្យ នៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឯករាជ្យ ឃ្លាំមើលនិងស្វែងរកការពិត របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលដោះស្រាយទាំងស្ថានភាពជាក់លាក់នៃប្រទេសនីមួយៗ ទាំងបញ្ហាតាមវិស័យមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួលគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគាត់បម្រើការក្នុងសមត្ថភាពបុគ្គលគាត់ផ្ទាល់ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍ពីការងាររបស់គាត់ដែរ។ ស្វែងយល់បន្ថែម សូមចូលទៅកាន់៖*

*http://www.ohchr.org/EN/Issues/FreedomOpinion/Pages/OpinionIndex.aspx*

***សូមឆែកមើលផងដែរ***នូវរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ខណៈពេលប្រឆាំងអំពើភេរវកម្ម *លោក* ***ប៊ិន អេមើសិន*** *(Ben Emmerson)*ដែលដោះស្រាយសិទ្ធិមនុស្សនៅក្នុងបរិបទនៃការបង្ការ និងប្រឆាំងអំពើរជ្រុលនិយមហិង្សា នៅក្នុងរបាយការណ៍ចុងក្រោយរបស់លោកដាក់ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស (*A/HRC/31/65*)៖
*http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session31/Documents/A.HRC.31.65_AUV.docx*

សម្រាប់ព័ត៌មានបន្ថែមនិង**ការស្នើសុំព័ត៌មាន** សូមទាក់ទងមក លោកស្រី វិចតូរៀ យុន (*Victoria Kuhn*) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩២៧៨ ឬ អ៊ីម៉ែល *vkuhn@ohchr.org*) ឬសរសេរទៅកាន់ *freedex@ohchr.org*.

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមកលោក ហ្សាប៊ៀរ សែឡាយ៉ា (Mr. Xabier Celaya) – អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)

**សម្រាប់វិបសាយព័ត៌មានរបស់លោក/អ្នក និងបណ្តាញសង្គម៖** មាតិកាពហុប្រព័ន្ធផ្សព្វផ្សាយ និងសារគន្លឹះៗទាក់ទងនឹងប្រកាសព័ត៌មានរបស់យើង អាចរកនោះលើឆាណែលបណ្តាញសង្គមសិទ្ធិមនុស្ស

អ.ស.ប ដែលមានរាយឈ្មោះខាងក្រោម។ សូមថេក (tag) មកយើង ដោយប្រើចំណុចបើកត្រឹមត្រូវ៖

ទ្វីតធឺ៖ @UNHumanRights

ហ្វេសប៊ុក៖ unitednationshumanrights

Instagram: unitednationshumanrights

ហ្គោហ្គិល៖ Google+: unitednationshumanrights

យូធូប៖ unohchr